# អ្នកផលិតចំណីសត្វ៖ អ្នកគឺជាអន្តរការី

ក្រុមហ៊ុនផលិតចំណីសត្វ

- អ្នកផលិតចំណីសត្វ បំពេញតួនាទីយ៉ាងសំខាន់ក្នុងការបន្តរក្សាប្រសិទ្ធភាព និងភាពអាចរកបាននៃ ឱសថប្រឆាំងមេរោគ។ តាមរយៈការកំណត់ថា ចំណីដែលប្រើប្រាស់សម្រាប់ព្យាបាលសត្វអាចទិញបានទាល់តែមានវេជ្ជបញ្ជា ពីបសុពេទ្យគេអាចទប់ទល់នឹងពពួកចំណី ដែលមានផ្ទុកជាតិឱសថប្រឆាំងមេរោគទាំងនេះលើសកម្រិត និងការប្រើប្រាស់មិនបានត្រឹមត្រូវ ដែលជាហេតុបង្កើនភាពសុំា ទៅនឹងឱសថប្រឆាំងមេរោគ។ សូមចាត់វិធានការនៅថ្ងៃនេះ ដើម្បីការពារឱ្យឱសថប្រឆាំងមេរោគ នៅតែបន្តប្រសិទ្ធភាពទៅថ្ងៃមុខទៀត។
- អ្នកផលិតចំណីសត្វ ដែលមានផ្ទុកជាតិឱសថប្រឆាំងមេរោគ គួរគោរពទៅតាមគោលការណ៍ណែនាំស្តីពីការអនុវត្តល្អ ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពសុំានៃឱសថប្រឆាំងមេរោគ។
- ក្នុងនាមជាអ្នកផលិតចំណីសត្វ វាជាការទទួលខុសត្រូវរបស់អ្នក។ ភាពជាអ្នកដឹកនាំ និងឥទ្ធិពលរបស់អ្នក មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ ដែលជាការបង្ហាញពីការបំពេញការងារប្រកបដោយវិជ្ជាជីវៈ និងការប្តេជ្ញាចិត្តរបស់អ្នកចំពោះវិស័យនេះ។

## អ្នកផលិតចំណីសត្វដែលមានផ្ទុកជាតិឱសថប្រឆាំងមេរោគគួរ៖

១ ទទួលបាន**ការអនុញ្ញាត** សម្រាប់ការផលិតចំណីសត្វដែលប្រើប្រាស់ឱសថប្រឆាំងមេរោគ និងគោរពតាមរាល់ការតម្រូវបមាណីយ៍នៃចំណីសត្វដែលមានឱសថប្រឆាំងមេរោគ។

២ ប្រើប្រាស់តែ**ប្រភពឱសថ ដែលមានការអនុញ្ញាតត្រឹមត្រូវ**។ ធានាថាឱសថដែលប្រើប្រាស់សម្រាប់បន្ថែមទៅក្នុងចំណីសត្វគឺជាពពួកឱសថមកពីប្រភពដែលមានការអនុញ្ញាតត្រឹមត្រូវ ប្រើប្រាស់ក្នុងកម្រិតមួយសមស្រប និងប្រើតែលើពពួកសត្វ និងសម្រាប់តែគោលបំណងដែលត្រូវបានបញ្ជាក់ក្នុងស្លាកសម្គាល់ឱសថទាំងនេះ ឬតាមវេជ្ជបញ្ជារបស់បសុពេទ្យតែប៉ុណ្ណោះ។

៣ **ចៀសវាងការចម្លងដោយភ្ជាក់ងារបង្ករោគ** និងការពារការចម្លងរោគ ដល់ចំណីដែលមិនមានឱសថប្រឆាំងមេរោគ។

៤ គោរពតាម **ការអនុវត្តល្អបំផុតលើការងារផលិតកម្ម** ដើម្បីបង្កើនអនាម័យ និងធ្វើការលាយផ្សំឱ្យបានសមស្រប ដើម្បីធានាថា នៅក្នុងចំណីសត្វ មានឱសថប្រឆាំងមេរោគតែមួយប្រភេទតែប៉ុណ្ណោះ។

៥ សូមផ្គត់ផ្គង់លក់ចំណីសត្វទាំងនេះ ដល់កសិករតែបន្ទាប់ពីមានការបង្ហាញ**វេជ្ជបញ្ជាពីបសុពេទ្យ**តែប៉ុណ្ណោះ។

៦ ធានាឱ្យមានការ **ដាក់ស្លាកសម្គាល់ឱ្យបានសមស្រប**(កម្រិតនៃការប្រើប្រាស់ឱសថ ការអះអាងដែលមានការបញ្ជាក់ត្រឹមត្រូវ អំពីប្រភេទសត្វ គោលដៅសម្រាប់ប្រភេទចំណីនីមួយៗ ការព្រមាន និងការប្រុងប្រយ័ត្ន) ដោយមានបញ្ជាក់ផលិតផល (សារធាតុផ្សំ អត្រាប្រើប្រាស់) ការណែនាំអំពីពេលដែលត្រូវប្រើប្រាស់ និងពេលដែលលែងប្រើប្រាស់។

៧ **រក្សាកំណត់ត្រាឱ្យបានសមស្រប** ដើម្បីឱ្យគេអាចតាមដានដឹងពីប្រភពដើម។

៨ សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និង**ចែករំលែកទិន្នន័យលក់ និងចែកចាយ** សម្រាប់គោលបំណងនៃការពិនិត្យតាមដានការប្រើប្រាស់ឱសថប្រឆាំងមេរោគ។




Funded by UK Government

WORLD ORGANISATION FOR ANIMAL HEALTH
*Protecting animals, preserving our future*